# រឿងទី២៖ លោកសាខេ

**ខគម្ពីរ៖ លូកា១៩:១០**

បុត្រមនុស្សបានមក ដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់»

នៅក្នុងក្រុងយេរីខូ មានមនុស្សមានមាឌតូចម្នាក់ឈ្មោះសាខេ។ គាត់ជាមេលើអ្នកទារពន្ធ។ អ្នកទារពន្ធគឺជាអ្នកដែលដើរប្រមូលពន្ធពីគេ។
លោកសាខេ មិនប្រមូលពន្ធតែពីអ្នកមានប៉ុណ្ណោះទេ គាត់ក៏បានបង្ខំអ្នកក្រីក្រឱ្យបង់ពន្ធផងដែរ។
ដូច្នេះហើយបានជាគេស្អប់គាត់ ហៅគាត់ថាជាមនុស្សបាប។ លោកសាខេប្រមូលពន្ធយ៉ាងច្រើន ហើយគាត់ក្លាយជាអ្នកមានដោយសារប្រាក់ដែលគាត់ប្រមូលមក។
មនុស្សទាំងអស់កាន់តែស្អប់លោកសាខេ។ ដូច្នេះហើយលោកសាខេតែងតែនៅម្នាក់ឯង។ នៅថ្ងៃមួយ ព្រះយេស៊ូយាងមកក្រុងយេរីខូ។
លោកសាខេ ចង់ស្គាល់ព្រះយេស៊ូណាស់ ដោយសារគាត់ធ្លាប់បានឮថាព្រះយេស៊ូយាងទៅតាមស្រុកភូមិ ព្យាបាលអ្នកមានជំងឺ បង្រៀនពីព្រះជាម្ចាស់។
លោកសាខេមិនអៀនអង់ គាត់បានប្រញាប់ប្រញាល់ដើម្បីទៅមើលព្រះយេស៊ូ។ ប៉ុន្តែ ដោយមានមនុស្សច្រើនពេក គាត់មិនអាចចូលទៅជិតដើម្បីឃើញព្រះយេស៊ូឡើយ។
ដោយសារតែលោកសាខេមានមាឌតូចពេក គាត់ក៏បានឡើងលើដើមឈើមួយ។
ពេលលោកសាខេកំពុងមើលព្រះយេស៊ូ ព្រះយេស៊ូឈប់ ងើបព្រះភក្ត្រឡើង ហើយមានព្រះបន្ទូលទៅកាន់គាត់ថា៖
«លោកសាខេអើយ! សូមអញ្ជើញចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះ ខ្ញុំត្រូវស្នាក់នៅផ្ទះលោក!»
ព្រះយេស៊ូមានព្រះបន្ទូលជាមួយគាត់ហាក់បីដូចជាមិត្តភក្តិដែលបានស្គាល់គ្នាយូរមកហើយ។
លោកសាខេក៏ចុះមកជាប្រញាប់ ហើយទទួលព្រះយេស៊ូដោយអំណរ។ កាលមនុស្សទាំងអស់ឃើញដូច្នោះ គេក៏បានរិះគន់។
ប៉ុន្តែព្រះយេស៊ូមិនយកព្រះទ័យទុកដាក់ឡើយ។

លោកសាខេទទួលព្រះយេស៊ូយ៉ាងអស់ពីចិត្ត។ គាត់ទូលព្រះយេស៊ូថា៖ «បពិត្រព្រះអម្ចាស់! ទូលបង្គំនឹងចែកទ្រព្យសម្បត្តិរបស់ទូលបង្គំ ចំនួនពាក់កណ្ដាលដល់មនុស្សក្រីក្រ ហើយប្រសិនបើទូលបង្គំទារពន្ធពីអ្នកណាហួសកម្រិត ទូលបង្គំនឹងសងអ្នកនោះវិញមួយជាបួន»។
ព្រះយេស៊ូមានបន្ទូលតបថា៖ «សាខេអើយ! ថ្ងៃនេះ ការសង្គ្រោះបានមកដល់ផ្ទះនេះហើយ! យើងមកដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់»។

លោកសាខេបានប្រែក្លាយជាមនុស្សថ្មី ក្រោយពេលបានជួបព្រះយេស៊ូ។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(លូកា១៩:១០)

ដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់



## សកម្មភាពទី១

សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



## សកម្មភាពទី២

ជួយលោកសាខេ ដើម្បីឱ្យគាត់បានជួបព្រះយេស៊ូ។

1. សូមផាត់ពណ៌ដើមឧទុម្ពរ រួចចោះរន្ធមួយនៅគល់ឈើ។ 2. សូមកាត់រូបលោកសាខេ រួចយកទៅបិទលើបន្ទះឈើ។
3. យកបន្ទះឈើទៅស៊កក្នុងរន្ធដែលបានចោះ រួចរុញចុះឡើង ធ្វើដូចជាលោកសាខេឡើងចុះលើដើមឈើ។





សម្ភារៈ៖ កន្ត្រៃ
ខ្មៅដៃពណ៌
បន្ទះឈើការ៉េម កាវ

រូបភាពរួចរាល់

